# កាលប្បវត្តិនៃវិសោធនកម្មរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា («រដ្ឋធម្មនុញ្ញ») ត្រូវបានសភាធម្មនុញ្ញអនុម័តជាផ្លូវការក្នុងសម័យប្រជុំពេញអង្គលើកទី២ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយបានប្រែក្លាយប្រទេសកម្ពុជាទៅរដ្ឋរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញត្រូវបានអតីតព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ និងបានក្លាយជាកាលបរិច្ឆេទប្រារព្ធទិវារដ្ឋធម្មនុញ្ញរៀងរាល់ឆ្នាំ។

កាលប្បវត្តិនេះផ្តល់នូវព័ត៌មាននៃការកែប្រែរដ្ឋធម្មនុញ្ញដែលត្រូវបានធ្វើឡើងតាមរយៈការធ្វើវិសោធនកម្មតាំងពីឆ្នាំ១៩៩៣ មក ដោយមិនធ្វើការវិភាគទៅលើវិសោធនកម្មទាំងនោះទេ។

# ១៩៩៤ - វិសោធនកម្មលើកទី១

វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទីមួយត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមនៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៤។ វិសោធនកម្មនេះបានកែសម្រួលមាត្រា២៨ ដោយថ្វាយសិទ្ធិអំណាចដល់ព្រះមហាក្សត្រក្នុងការផ្ទេរអំណាចឡាយព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យទៅប្រមុខរដ្ឋស្ដីទីចុះហត្ថលេខាជំនួស នៅពេលអង្គព្រះមហាក្សត្រអវត្តមាន។

# ១៩៩៩ - វិសោធនកម្មលើកទី២

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ ព្រះបាទនរោត្តម សីហនុ បានឡាយព្រះហស្តលេខាលើ វិសោធនកម្មមាត្រា១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ។ វិសោធនកម្មលើកទីពីរនេះផ្តោតសំខាន់ទៅលើការបង្កើតស្ថាប័នព្រឹទ្ធសភា និងការកំណត់តួនាទី និងមុខងាររបស់ស្ថាប័ននីតិប្បញ្ញត្តិមួយនេះ។

# ២០០១ - វិសោធនកម្មលើកទី៣

វិសោធនកម្មទីបីត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០១ ដោយកែសម្រួលមាត្រា១៩ និង២៩ ។ ការផ្លាស់ប្តូរទាំងនេះទាក់ទងនឹងការតែងតាំងនាយករដ្ឋមន្ត្រី និងទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងសិទ្ធិអំណាចរបស់ព្រះមហាក្សត្រក្នុងការបង្កើត និងប្រគល់គ្រឿងឥស្សរិយសជាតិ ព្រមទាំងការប្រទានឋានន្តរសក្តិ ឋានៈ ស៊ីវិល និងយោធា។

# ២០០៤ - វិសោធនកម្មលើកទី៤

នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ប្រមុខរដ្ឋស្ដីទីបានប្រកាសឱ្យប្រើ «ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ»។[1] ច្បាប់ដែលមាន ៧ មាត្រានេះមានគោលបំណងធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍មូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់។

[1] ច្បាប់រដ្ឋធម្មនុញ្ញបន្ថែមនេះត្រូវបានអនុម័តឡើងបន្ទាប់ពីភាពជាប់គាំងនយោបាយអស់រយៈពេលជិតមួយឆ្នាំដែលបានបង្កការរាំងស្ទះដល់ការបង្កើតរដ្ឋាភិបាលថ្មី។

# ២០០៥ - វិសោធនកម្មលើកទី៥

ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៥ ត្រូវបានព្រះមហាក្សត្រប្រកាសឱ្យប្រើនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដោយកែប្រែមាត្រា៨៨ និងមាត្រា១១១ (ថ្មី)។ ការធ្វើវិសោធនកម្មនេះទាក់ទងនឹងការកែប្រែកូរ៉ុមសម្រាប់សមាជិកសភា និងសមាជិកព្រឹទ្ធសភាដើម្បីបោះឆ្នោតអនុម័តជាផ្លូវការទៅលើអ្វីមួយ។

# ២០០៦ - វិសោធនកម្មលើកទី៦

វិសោធនកម្មលើកទីប្រាំមួយ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៦ បាន កែប្រែមាត្រា៨២, ៨៨ (ថ្មី), ៩០ (ថ្មី), ៩៨, ១០៦ (ថ្មី), ១១១ (ថ្មី), ១១៤ (ថ្មី) និង មាត្រា៦ នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម។ ការផ្លាស់ប្តូរសំខាន់ចេញពីវិសោធនកម្មនេះគឺការកាត់ បន្ថយនូវសំឡេងបោះឆ្នោតទុកចិត្តដល់រដ្ឋាភិបាលពីសំឡេងពីរភាគបី ទៅជាសំឡេងភាគ ច្រើនដាច់ខាត (៥០%+១) នៃសមាជិករដ្ឋសភា។

# ២០០៨ - វិសោធនកម្មលើកទី៧

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្មលើកទី៧ ដោយកែប្រែមាត្រា ១៤៥ និងមាត្រា ១៤៦ ដែលពាក់ព័ន្ធនឹងការបែងចែករដ្ឋបាលទឹកដីនៃប្រទេសកម្ពុជាទៅជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

# ២០១៤ - វិសោធនកម្មលើកទី៨

នៅខែតុលា ឆ្នាំ២០១៤ រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី ១៥ (ថ្មី) ដល់ជំពូកទី១៦ (ថ្មី)។ ការផ្លាស់ប្តូរសំខាន់គឺទាក់ទងនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោយបង្កើតទៅជាស្ថាប័នឯករាជ្យដែលមានអំណាចកំណត់តាមរដ្ឋធម្មនុញ្ញ។ តាមមាត្រាដែលបានធ្វើបច្ចុប្បន្នភាព គ.ជ.ប ដែលមានសមាជិកចំនួនប្រាំបួនរូប៖ សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សផ្សេងទៀតមានអាសនៈក្នុងរដ្ឋសភា និងមួយរូបត្រូវជ្រើសរើសដោយមានការព្រមព្រៀងពីគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា (មាត្រា ១៥១ - ថ្មី ២)។ វិសោធនកម្មនេះផ្តើមចេញពីកិច្ចព្រមព្រៀងរវាងគណបក្សកាន់អំណាច និងគណបក្សសង្គ្រោះជាតិ ដើម្បីបញ្ចប់ការធ្វើពហិការរបស់គណបក្សជំទាស់ ក្នុងការចូលរដ្ឋសភា ក្រោយការបោះឆ្នោតឆ្នាំ២០១៣។

# ២០២១ - វិសោធនកម្មលើកទី៩

វិសោធនកម្មលើកទី៩ ដែលត្រូវបានប្រកាសឱ្យប្រើក្នុងខែវិច្ឆិកា ឆ្នាំ២០២១ បានកែប្រែមាត្រា១៩ (ថ្មី), ៨២ (ថ្មី), ១០៦ (ថ្មី១), ១១៩ (ថ្មី), និង ១៣៧ (ថ្មី) នៃរដ្ឋធម្មនុញ្ញ ព្រមទាំងមាត្រា៣ និង៤ នៃច្បាប់ធម្មនុញ្ញបន្ថែម។ ការផ្លាស់ប្តូរចម្បងនៃវិសោធនកម្មនេះ គឺតម្រូវឱ្យបុគ្គលដែលមានតួនាទីខ្ពស់បំផុតនៅស្ថាប័នជាតិកំពូល ដូចជានាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវមានសញ្ជាតិខ្មែរតែមួយគត់។

# ២០២២ - វិសោធនកម្មលើកទី១០

នៅខែសីហា ឆ្នាំ២០២២ មានការធ្វើវិសោធនកម្មមាត្រា ១៩ (ថ្មី ១) ៨៩, ៩៨ (ថ្មី) ១០២ (ថ្មី), ១១៩ (ថ្មី ១), និង ១២៥ (ថ្មី) នៃរដ្ឋធម្មនុញ្ញ ព្រមទាំងមាត្រា ៣ (ថ្មី) និង ៤ (ថ្មី) នៃច្បាប់ធម្មនុញ្ញបន្ថែម។ វិសោធនកម្មទាំងនេះផ្តោតទៅលើការតែងតាំងនាយករដ្ឋមន្ត្រី និង និងដំណើរការជាប្រក្រតីនៃស្ថាប័ននីតិប្បញ្ញត្តិ។ ការកែប្រែសំខាន់មួយ គឺវិសោធនកម្មមាត្រា ១១៩ (ថ្មី ១) បានចែងថា គណបក្សនយោបាយដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភាមានសិទ្ធិចាត់តាំងរជនមួយរូបជានាយករដ្ឋមន្ត្រីដោយផ្ទាល់។ ខុសពីនិតីវិធីមុនដោយការចាត់តាំងតែងរជនជានាយករដ្ឋមន្ត្រីត្រូវបោះឆ្នោតសុំសេចក្តីទុកចិត្តពីរដ្ឋសភា។

# ២០២៥ - វិសោធនកម្មលើកទី១១

កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ ព្រះមហាក្សត្របានឡាយព្រះហស្តលេខាលើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញ កែប្រែអនុញ្ញាតឱ្យមានការដកសញ្ជាតិខ្មែរដែលត្រូវកំណត់ក្នុងច្បាប់។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដំបូងឡើយមាន១៤ ជំពូក និង១៣៩ មាត្រា។ បន្ទាប់ពីការធ្វើវិសោធនកម្មជាច្រើនលើក មកដល់ពេលនេះរដ្ឋធម្មនុញ្ញមាន១៧ ជំពូក និង១៦០ មាត្រា។ វិសោធនកម្មចុងក្រោយបំផុតត្រូវបានធ្វើឡើងនៅខែកក្កដា ឆ្នាំ២០២៥៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

២៤ កញ្ញា ២០២៦

CC BY NC SA